ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ៣៣

ចុះថ្ងៃទី ២២ . ៦ . ៩៩

សាលដីកា

លេខ : ៤៦

ចុះថ្ងៃទី ០៦ . ៩ .២០០០

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០០ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះ ដូចតទៅ :

១ - ឯកឧត្តម ឃឹម ប៉ុណ្ណ ប្រធាន

២ - លោក សោម សិរីវឌ្ឍ ចៅក្រមរបាយការណ៍

៣ - លោក ឈឹម ស៊ីផល ចៅក្រម

៤ - លោក ទេវ៉ុល មួន ចៅក្រម

៥ - លោក ព្រាក់ គឹមសាន ចៅក្រម

លោក ហុក សុប ក្រឡាបញ្ជី

តំណាងមហាអយ្យការឯកឧត្តម ជួន ស៊ិនទៀង អគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ ៧៨ ចុះថ្ងៃទី ០២ ៤.៩៩ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ ៣៣ ចុះថ្ងៃទី ២២.៦.៩៩របស់តុលាការកំពូល ។

ពីបទ : សំលាប់មនុស្សគិតទុកជាមុនប្រព្រឹត្តនៅភូមិសំរោង ឃុំក្រាំងយ៉ូវ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី ១៨.៨.៩៦ បទល្មើសដែលមានចែងតាមបញ្ញត្តិមាត្រា ៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- ជនជាប់ចោទឈ្មោះ ហ៊ិន នឹម " ជាចុងបណ្តឹងសាទុក្ខ " ភេទស្រី អាយុ ១៦ ឆ្នាំ ជាតិខ្មែរ កើតនៅភូមិក្រាំងយ៉ូវ ឃុំក្រាំងយ៉ូវ ស្រុកស្អាង ខេត្តកណ្តាល របរទក ស៊ីធ្វើស្រែ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិសំរោង ឃុំក្រាំងយ៉ូវ ស្រុកស្អាង ខេត្ត - កណ្តាល ឪពុកឈ្មោះ វ៉ាន ហ៊ិន " រ " ម្តាយឈ្មោះ រ៉ុត យ៉ាង " រ " ។ នៅលីវ ។ ទោសពីមុនគ្មាន ឃុំខ្លួនថ្ងៃទី ២៣.៨.៩៦ ។

មេធាវី : លោក ល្អង សុខា

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ គ្រី យូវ " ជាម្ចាស់បណ្តឹងសាទុក្ខ " ភេទប្រុស អាយុ ៤៧ ឆ្នាំ ជាតិខ្មែរ កើតនៅភូមិក្រាំងស្លែង ឃុំតពាំងសាប ស្រុកបាទី ខេត្តតាកែវ

របររកស៊ីធ្វើស្រែ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិលំពាង ឃុំក្រាំងយ៉ូវ ស្រុកស្អាង ខេត្តកណ្ដាល ឪពុកឈ្មោះ ឃុំ គ្រី " ស " ម្ដាយឈ្មោះ ក្រាំង ស្រ៊ាវ " ស " ប្រពន្ធឈ្មោះ - អ៊ី ឡាយ មានកូន ១០ នាក់ ។

មេធាវី ៖ គ្មាន

- តាមបណ្ដឹងសារទុក្ខលេខ ៣០ ចុះថ្ងៃទី ០២.៤.៩៥ របស់ឈ្មោះ គ្រី យូរ ដែលប្ដឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ៧៨ ចុះថ្ងៃទី ០២.៤.៩៥ របស់សាលាឧទ្ធរណ៍លើសេចក្ដីសំរេចទាំងមូល ។

- តាមពាក្យបណ្ដឹងរបស់ឈ្មោះ គ្រី យូរ ចុះថ្ងៃទី ១៩.៨.៩៦ បានបញ្ជាក់ថា កាលពីថ្ងៃទី ១៨.៨.៩៦ បានបាត់កូនស្រីឈ្មោះ យូរ ស្រីផា អាយុ ១១ ឆ្នាំ វេលាម៉ោង ៣ រសៀល ហើយបានរកឃើញនៅវេលាម៉ោង ៧ និង ៣០ នាទីព្រឹកថ្ងៃទី ១៩.៨.៩៦ នៅក្រោយផ្ទះចំងាយប្រហែល ៥០ម៉ែត្រ ក្នុងប្រឡាយទឹកដោយបាត់ក្រវិលមួយគូទំងន់ ៥ ហ៊ុនមាស ដើមបណ្ដឹងសំណូមពរសុំក្រវិលមាសមកវិញ ដើម្បីយកដោះស្រាយជីវភាព និង សុំអោយផ្ដន្ទាទោសជនល្មើសទៅតាមច្បាប់ និង សុំជំងឺចិត្តចំនួន ១០ លានរៀល ។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ អម តុលាការខេត្តកណ្ដាល ៖ សំរេចចោទប្រកាន់លើឈ្មោះ ហ៊ិន នឹម ពីបទមនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅភូមិលំពាង ឃុំក្រាំងយ៉ូវ ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី ១៨.៨.៩៦ តាមដីកាឃុំខ្លួនលេខ ១៥៥ ដកឃ១-៩៦ ចុះថ្ងៃទី ២៣.៨.៩៦ ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៥៣ " ព " ចុះថ្ងៃទី ១៧.១២.៩៦ របស់តុលាការខេត្តកណ្ដាល ដែលបានសំរេច ៖

១- ផ្ដន្ទាទោសឈ្មោះ ហ៊ិន នឹម ឈ្មោះក្រៅគ្មាន ភេទស្រី អាយុ ១៩ ឆ្នាំ ដាក់ពន្ធនាគារចំនួន ១៥ ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី [illegible].៨.៩៦ ។

ពីបទ ឃាតមនុស្សគិតទុកជាមុន ប្រព្រឹត្តនៅភូមិលំពាង ឃុំក្រាំងយ៉ូវ ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី ១៨.៨.៩៦ ។

២- បង្គាប់អោយឈ្មោះ ហ៊ិន នឹម សងជំងឺចិត្តអោយទៅឈ្មោះ គ្រី យូរ ជាប្រាក់ចំនួន ៣លានរៀល សំណងលើសពីនេះត្រូវលើកចោល ។

ក្នុងករណីឈ្មោះ ហ៊ិន នឹម គ្មានប្រាក់សងធនទណ្ឌគ្រប់ចំនួនត្រូវដាក់គុកបង្ខំរូបកាយ ដើម្បីទារប្រាក់ធនទណ្ឌតាមកំណត់ច្បាប់ ។

៣- វត្ថុតាង ៖ មានក្រវិលមាសមួយគូទំងន់ ៥ហ៊ុន របស់ជនរងគ្រោះត្រូវប្រគល់អោយឈ្មោះ គ្រី យូរ ជាឪពុកជនរងគ្រោះវិញ ឯសំពត់ស្បែកយឺតមួយពណ៌ក្រហមផ្កាចំនុះ អាវយឺតដៃខ្លីមួយបង្គងពណ៌ស-ខៀវ ស្បែកជើងផ្ទាត់ពណ៌សមួយគូ ខ្សែរគោមួយសរសៃប្រវែង ជាងមួយម៉ែត្រ ពោះវៀនកង់ពណ៌ខ្មៅមួយ កំទេចក្រណាត់មួយស្បោង និង កំទេចកៅស៊ូមួយស្បោង ត្រូវដុតបំផ្លាញចោល ។

-- --

៤ - សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ និង កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ។

- បានឃើញបណ្តឹងឧទ្ធរណ៍ ០២ ចុះថ្ងៃទី ២២.០១.៩៧ របស់ឈ្មោះ ហ៊ិន នីម ដែលប្តឹងតវ៉ាពីសាលក្រមព្រហ្មទណ្ឌលេខ ៥៣ " ព " ចុះថ្ងៃទី ១៧.១២.៩៦ របស់តុលាការខេត្តកណ្តាលលើសេចក្តីសំរេចនៃសាលដីកាទាំងមូល ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អម សាលាឧទ្ធរណ៍ថា ៖

១ - ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២២.០១.៩៧ របស់ជនជាប់ចោទឈ្មោះ ហ៊ិន នីម ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែលើកចោលដោយខុសនឹងនីតិច្បាប់ ។

២ - តំកល់សាលក្រមព្រហ្មទណ្ឌលេខ ៥៣ " ព " ចុះថ្ងៃទី ១៧.១២.៩៦ របស់តុលាការខេត្តកណ្តាលទាំងមូល តែគួរបន្ថែមមាត្រា ៧ នៃច្បាប់ស្តីពីការដាក់គុកបង្ខំរូបកាយក្នុងរឿងព្រហ្មទណ្ឌត្រង់ចំណុចទី ២ នៃសេចក្តីសំរេចរបស់សាលក្រម ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ៧៨ ចុះថ្ងៃទី ០២.៤.៩៨ របស់សាលាឧទ្ធរណ៍ដែលបានសំរេច ៖

១ - ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២២.០១.៩៧ របស់ឈ្មោះ ហ៊ិន នីម ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងនីតិច្បាប់ ។

២ - តំកល់សាលដីកាព្រហ្មទណ្ឌលេខ ៥៣ " ព " ចុះថ្ងៃទី ១៧.១២.៩៦ របស់តុលាការខេត្តកណ្តាល ទុកជាបានការដដែល ដោយគ្រាន់តែបន្ថយរយៈពេលផ្តន្ទាទោសពី ១៥ ឆ្នាំមក ៦ ឆ្នាំវិញ តាមមាត្រា ៦៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចំណុចក្រៅពីនេះទុកជាបានការដដែល ។

៣ - សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

- បានឃើញបណ្តឹងសាទុក្ខលេខ ៣០ ចុះថ្ងៃទី ០២.៤.៩៨ របស់ឈ្មោះ គ្រី យូរ ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ៧៨ ចុះថ្ងៃទី ០២.៤.៩៨ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចនៃសាលដីកាទាំងមូល ។

- បានចេញលិខិតបង្គាប់អោយធ្វើសារណាចុះថ្ងៃទី ២៦.១០.៩៨ ដើមបណ្តឹងសាទុក្ខបានផ្តិតមេដៃទទួលថ្ងៃទី ០៩.១១.៩៨ តែពុំឃើញដាក់សារណាផ្ញើមកតុលាការកំពូលទេ ជាហេតុនាំអោយគ្មានសារណាតបរបស់ជនជាប់ចោទឈ្មោះ ហ៊ិន នីម ។

- បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អម តុលាការកំពូល ថា ៖ មានពិរុទ្ធគ្រប់គ្រាន់លើឈ្មោះ ហ៊ិន នីម ពីបទធ្វើមនុស្សឃាតគិតទុកជាមុន តែដោយជនជាប់ចោទជាអនីតិជន ការសំរេចរបស់សាលាឧទ្ធរណ៍គឺជាការត្រឹមត្រូវហើយ ។

- បានស្តាប់ចំលើយអះអាងរបស់ឈ្មោះ គ្រី យូរ ជាម្ចាស់បណ្តឹងសាទុក្ខនៅពេលសវនាការថា ៖

តុលាការខេត្តកណ្ដាលបានកាត់ដាក់គុក ១៥ ឆ្នាំ ប្រាក់ ៣ លានរៀល មកសាលាឧទ្ធរណ៍នៅសល់តែ ៦ ឆ្នាំ បញ្ហានេះសូមតុលាការមេត្តាពិចារណាផង ។

- បានស្ដាប់ចំលើយដោះសាររបស់ឈ្មោះ ហិន នីម ជាចុងបណ្ដឹងសាទុក្ខនៅពេលសវនាការថា : សុំតុលាការមេត្តាសណ្ដោស ព្រោះនាងខ្ញុំនៅក្មេងមិនចេះគិត មានភាពល្ងង់ខ្លៅ ចំពោះប្រាក់សំណងទីពុកម្ដាយខ្ញុំចាស់ពុកហើយ ពុំមានប្រាក់សងទេ ។

- បានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់លោក ល្អង សុខា ជាមេធាវីការពារក្ដីអោយឈ្មោះ ហិន នីម ជាចុងបណ្ដឹងសាទុក្ខនៅពេលសវនាការថា : កូនក្ដីរបស់ខ្ញុំបាទបានសារភាពនូវអង្គហេតុរួចហើយ សាលាឧទ្ធរណ៍ដែលបានសំរាលទោសអោយកូនក្ដីខ្ញុំបាទដែលជាអនីតិជនតាមមាត្រា ៦៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល សំណូមពររបស់ខ្ញុំបាទសូមតុលាការកំពូលមេត្តាតម្កល់សាលដីកាសាលាឧទ្ធរណ៍ទាំងមូល ។

- បានស្ដាប់សេចក្ដីសន្និដ្ឋានបន្ថែមនាពេលសវនាការរបស់តំណាងមហាអយ្យការ អម តុលាការកំពូលថា : សូមរក្សាសេចក្ដីសន្និដ្ឋានដដែល ។

- ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានស្ដាប់ចំលើយដោះសាររបស់ដើមបណ្ដឹងរដ្ឋប្បវេណី- ជនជាប់ចោទ និង សេចក្ដីសន្និដ្ឋានរបស់មេធាវីជនជាប់ចោទ .

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុ លា កា រ កំ ពូ ល

- យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ៣០ ចុះថ្ងៃទី ០២.៥.៩៩ របស់ឈ្មោះ គ្រី យូរ ធ្វើទៅឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្ដីពីការចាត់តាំង និង សកម្មភាពរបស់តុលាការជំរះក្ដី ។

- យល់ឃើញថា មានពិរុទ្ធភាពគ្រប់គ្រាន់ក្នុងការផ្ដន្ទាទោសឈ្មោះ ហិន នីម អំពីបទសំលាប់មនុស្សគិតទុកជាមុន ប្រព្រឹត្តនៅភូមិសំរោង ឃុំក្រាំងយ៉ូវ ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី ១៨.៩.៩៦ បទល្មើសដែលមានចែងនិងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- យល់ឃើញថា ការដែលដើមបណ្ដឹងរដ្ឋប្បវេណីទាមទារអោយផ្ដន្ទាទោសជនជាប់ចោទដូចនៅតុលាការខេត្តនោះ តុលាការកំពូលពុំអាចសំរេចបានទេឡើយ ពីព្រោះថានៅពេលប្រព្រឹត្តបទល្មើសជនជាប់ចោទមានវ័យក្នុងអាយុ ១៦ ឆ្នាំ ហើយពុំដែលធ្លាប់បានត្រូវផ្ដន្ទាទោសពីមុនមកទេ ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៧៨ ចុះថ្ងៃទី ០២.៥.៩៩ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្ដីមកនេះមានលក្ខណៈត្រឹមត្រូវទាំងទំរង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី

១ - ទទួលបណ្តឹងសាទុក្ខលេខ ៣០ ចុះថ្ងៃទី ០២.៤.៩៩ របស់ឈ្មោះ គ្រី យូន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២ - តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៧៨ ចុះថ្ងៃទី ០២.៤.៩៩ របស់សាលាឧទ្ធរណ៍ទុកជាបានការ ពេញទាំងមូល ។

៣ - សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០០០ ។